00335587

E39/4/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| **ដាក់ទៅ:** | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់:** | ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ |
| **ភាគីអ្នកដាក់:** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម:** | អង់គ្លេស |
| **ប្រភេទឯកសារដែលស្នើឡើង:** | **សាធារណៈ** |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 06 / 2009
ម៉ោង (Time/Heure): 15 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# យោបល់របស់សហព្រះរាជអាជ្ញានៅលើសំណុំរឿងរបស់តុលាការយោធា

**<u>អ្នកដាក់ឯកសារ:</u>**

**ការិ.សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Alex BATES
លោក ពេជ្រ សម្បត្តិ
លោក Stuart FORD

**<u>អ្នកទទួលឯកសារ:</u>**

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**<u>ចម្លងជូន៖</u>**

**ជនជាប់ចោទឈ្មោះ៖**
កាំង ហ្គេកអ៊ាវ *ហៅ* "ឌុច"

**មេធាវីរបស់ជនជាប់ចោទ៖**
លោក ការ សាវុត្ថ
លោក François ROUX

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
លោក គឹម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Silke STUDZINSKY
លោកស្រី Martine JACQUIN
លោក Philippe CANNONE

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## ១. សេចក្ដីផ្ដើម

១. នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ មេធាវីការពារក្ដីបានស្នើសុំដោយផ្ទាល់មាត់ ឱ្យដោះលែងជនចោទជាប់[1] ។ មេធាវីការពារក្ដី បានដាក់បន្ថែមទៅនឹងសំណើផ្ទាល់មាត់នេះ នូវអំណះអំណាងជាលាយលក្ខណ៍អក្សរមួយ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩[2] ។ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្ដីសម្រេចមួយ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៩ ដែលនៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូង បានជំរាបជូនភាគីថា ខ្លួនបានស្នើសុំសំណុំឯកសារជាច្បាប់ចម្លងមួយច្បាប់របស់ជនជាប់ចោទ ពីតុលាការយោធា ("ចាប់ពីនេះតទៅហៅថា "សំណុំរឿងរបស់តុលាការយោធា") និងថា សំណុំរឿងរបស់តុលាការយោធានេះ ត្រូវតែបានបកប្រែជាភាសាអង់គ្លេស និង បារាំង[3] ។ ក្នុងពេលដូចគ្នានេះដែរ អង្គជំនុំជម្រះ បានជូនដំណឹងដល់ភាគីថា "បន្ទាប់ពីបានទទួលច្បាប់បកប្រែនៃសំណុំរឿងរបស់តុលាការយោធា ភាគីនឹងមានរយៈពេល១០ថ្ងៃ ដើម្បីមានយោបល់"[4] ។

២. នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសផ្ទាល់មាត់នៅក្នុងអម្លុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការថា ទោះបីជាសំណុំរឿងរបស់តុលាការយោធាមិនបានបកប្រែគ្រប់ផ្នែកទាំងអស់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង ជឿថា ផ្នែកដែលមិនទាន់បានបកប្រែទាំងនោះ គឺជាផ្នែកដែលមិនសំខាន់ណាស់ណាទេ ។ ស្របគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគីថា ភាគីមានពេលវេលារហូតដល់ម៉ោង ៤ ល្ងាច ថ្ងៃច័ន្ទ ទី០១ ខែមិថុនា ឆ្នាំ២០០៩ ដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះ អំពីយោបល់ណាមួយដែលខ្លួនមាន នៅលើសំណុំរឿងតុលាការយោធានេះ ។

---

[1] *សូមអាន* ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩, សំណុំរឿងលេខ: E1/7.1, ERN 00302241-00302320 (ភាសាខ្មែរ) ERN 00302027-00302128 (ភាសាអង់គ្លេស) ត្រង់ទំព័រទី ២០-៣២ ។

[2] *សូមអាន* អំណះអំណាងបន្ថែមរបស់ក្រុមការពារក្ដីដើម្បីគាំទ្រដល់សំណើរបស់ខ្លួនទាក់ទងនឹងបញ្ហាទោស, ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ ២០០៩, សំណុំរឿងលេខ: E39/3, ERN 00315430-00315434 (ភាសាខ្មែរ) ERN 00323787-00323790 (ភាសាអង់គ្លេស) ។

[3] *សូមអាន* សេចក្ដីសម្រេចពន្យាររយៈពេលកំណត់ ដើម្បីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទនៅក្រៅឃុំ, ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩,សំណុំរឿងលេខ: E39/4, ERN 00317553-00317557 (ភាសាខ្មែរ) ERN 00317550-00317552 (ភាសាអង់គ្លេស)។

[4] *ដូចខាងលើ* ។

## ២. យោបល់របស់សហព្រះរាជអាជ្ញា

៣. សហព្រះរាជអាជ្ញាជឿថា ខ្លឹមសារនៃសំណុំរឿងរបស់តុលាការយោធា គឺមានការពាក់ព័ន្ធគ្នាទៅនឹងការដោះស្រាយលើសំណើរបស់មេធាវីការពារក្តី ដែលស្នើសុំឱ្យមានការដោះលែងជនជាប់ចោទជាបន្ទាន់ ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា មិនមានយោបល់នៅលើខ្លឹមសារនៃសំណុំរឿងរបស់តុលាការយោធានេះទេ ។

៤. នៅក្នុងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នរបស់ខ្លួន ទាក់ទងទៅនឹងជនជាប់ចោទ នៅក្នុងខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានថា អ.វ.ត.ក មិនបានចូលរួមនៅក្នុងការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធា មិនបានធ្វើសកម្មភាពដោយមានការព្រមព្រៀងគ្នាណាមួយជាមួយតុលាការយោធា និងជាក់ស្តែង រហូតមកទល់នឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ ក៏ជនជាប់ចោទមិនទាន់មានវត្តមាននៅ អ.វ.ត.ក នៅឡើយដែរ [5] ។ ផ្អែកតាមនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានថា ពួកគេមិនមានយុត្តាធិការដើម្បីធ្វើការជំនុំជម្រះអំពីនីយតភាពនៃការឃុំខ្លួនរបស់ជនជាប់ចោទ ដោយតុលាការយោធានោះឡើយ និងថា ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធាគឺមិនអនុញ្ញាតឱ្យ អ.វ.ត.ក ចេញដីកាដោះលែងបានទេ[6] ។

៥. ជនជាប់ចោទបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញា ទទួលស្គាល់ថា ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធាអាចនឹងបណ្តាលឱ្យមាន "ការបន្ធូរបន្ថយទោសនៅក្នុងពេលកាត់ឱ្យជាប់ទោស"[7] ។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ថា ជនជាប់ចោទមិនត្រូវមានសិទ្ធិដើម្បីទទួលនូវការដោះ

---

[5] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣១ កក្កដា ២០០៧, សំណុំរឿងលេខ C3, ERN 00145478-00145488 (ភាសាខ្មែរ) ERN 00145458-00145468 (ភាសាអង់គ្លេស) ត្រង់កថាខណ្ឌទី២០ ។

[6] *ដូចខាងលើ* ។

[7] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី៣ តុលា ២០០៧, សំណុំរឿងលេខ: C5/8, ERN 00154557-00154603 (ភាសាខ្មែរ) ERN 00155243-00155270 (ភាសាអង់គ្លេស) ត្រង់កថាខណ្ឌទី៩២ ។

លែងជាបន្ទាន់ដែរ ពីព្រោះ អ.វ.ត.ក មានឯករាជ្យភាពទាំងស្រុងពីតុលាការយោធា ហើយ អ.វ.ត.ក មិនធ្វើសកម្មភាពដោយមានការព្រមព្រៀងណាមួយជាមួយតុលាការយោធា ក្នុងការឃុំខ្លួនជនជាប់ចោទនោះដែរ ។ ហេតុដូចនេះ សកម្មភាពទាំងឡាយរបស់តុលាការយោធា គឺមិនអាចទម្លាក់កំហុសមកលើ អ.វ.ត.ក បានឡើយ[8] ។

៦. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះកាំង ហ្កេកអ៊ាវ ហៅ ឌុច អង្គបុរេជំនុំជម្រះបានយល់ស្របចំពោះមូលហេតុដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ។ អង្គបុរេជំនុំជម្រះ បានធ្វើសេចក្តីសន្និដ្ឋានថា អ.វ.ត.ក គឺមានភាពឯករាជ្យពីតុលាការយោធា និងថា “សម្រាប់រាល់គោលបំណងផ្នែកអនុវត្តន៍ និងតាមផ្លូវច្បាប់ទាំងអស់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យមួយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា ហើយហេតុដូចនេះ គឺមិនមានយុត្តាធិការដើម្បីធ្វើការវិនិច្ឆ័យ ទៅលើសកម្មភាពនានារបស់ស្ថាប័នដទៃៗទៀតឡើយ”[9] ។ អង្គជំនុំជម្រះក៏បានធ្វើសេចក្តីសន្និដ្ឋានផងដែរថា ក្នុងកាលៈទេសៈណាមួយក៏ដោយ នៅមុនថ្ងៃដែលវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ត្រូវបានអនុម័ត តុលាការយោធាមិនអាចត្រូវបានចាត់ទុកថា បានធ្វើការងារដោយមានការទាក់ទងគ្នាទៅវិញទៅមកជាមួយ ឬ ក្រោមការណែនាំរបស់ អ.វ.ត.ក នោះឡើយ[10] ។ ផ្អែកតាមនេះ បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ គឺត្រូវតែបានបដិសេធចោល ។

៧. សេចក្តីសម្រេចទាំងនេះ បង្ហាញថា អ.វ.ត.ក គឺឯករាជ្យពីតុលាការយោធាហើយថា ចំណាត់ការទាំងឡាយរបស់តុលាការយោធា មិនអាចត្រូវបានទម្លាក់ការទទួលខុសត្រូវលើ អ.វ.ត.ក បានទេ ។ ដោយឡែកនៅក្នុងចំណាត់ការដែលបានធ្វើឡើងជាច្រើនឆ្នាំមុនពេលដែល អ.វ.ត.ក មានវត្តមាន មិនអាចទម្លាក់ការទទួលខុសត្រូវលើ អ.វ.ត.ក បានទេ ទោះបីជាតុលាការយោធា

---

[8] *ដូចខាងលើ* ត្រង់កថាខណ្ឌទី៧៧-៨៣ ។

[9] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួន កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាបណ្តោះអាសន្ន ចុះថ្ងៃទី៣ ធ្នូ ២០០៧ សំណុំរឿងលេខ C5/45, ERN 00154259-00154283 (ភាសាខ្មែរ) ERN 00154284-00154302 (ភាសាអង់គ្លេស) ត្រង់កថាខណ្ឌទី ១៦-២២ ។

[10] *ដូចខាងលើ* ត្រង់កថាខណ្ឌទី២២ ។

ចាត់ការយ៉ាងណាក៏ដោយ ។ លើសពីនេះ អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីធ្វើការវិនិច្ឆ័យលើនីត្យានុកូលភាពនៃដំណើរការនីតិវិធី នៅចំពោះមុខតុលាការយោធាទេ ។ ដូច្នេះ សំណុំរឿងរបស់តុលាការយោធា ពុំមានការទាក់ទងគ្នាទេ ។

៨. ដូចដែលសហព្រះរាជអាជ្ញា បានធ្វើការកត់សម្គាល់នៅក្នុងអំឡុងពេលនៃបណ្តឹងឧទ្ធរណ៍ លើកមុន អំពីបញ្ហានេះជូនទៅអង្គបុរេជំនុំជម្រះ ថាជនជាប់ចោទអាចនឹងមានសិទ្ធិទទួលបាននូវ "ការបន្ធូរបន្ថយទោសនៅក្នុងករណីដែលមានការកាត់ឱ្យជាប់ទោស" ដោយគិតពីរយៈពេលនៃការឃុំខ្លួនមុនមានការជំនុំជម្រះ លើអង្គសេចក្តី ។ ក្នុងបរិបទនេះ សហព្រះរាជអាជ្ញាទទួលស្គាល់ថា ជនជាប់ចោទបានជាប់នៅក្នុងមន្ទីរឃុំឃាំង ចាប់តាំងពីថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៩ ដែលជារយៈពេលមួយ មានចំនួនជាង១០ឆ្នាំ មកហើយ ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏ខ្លឹមសារនៃសំណុំរឿងរបស់តុលាការយោធា ពុំមានការទាក់ទងទៅនឹងសំណើរបស់ជនជាប់ចោទសុំឱ្យមានការដោះលែងជាបន្ទាន់នោះទេ ។

## ៣. សេចក្តីសន្និដ្ឋាន

៩. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា មិនមានយោបល់ទៅលើខ្លឹមសារនៃសំណុំរឿងរបស់តុលាការយោធាទេ ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩
**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** លោក Robert PETIT